multicultural health communication

ANDROLOGY AUSTRALIA

Khmer
[OTH-7650]

# សេចក្តីណែនាំសំរាប់ប្រជាពលរដ្ឋប្រើប្រាស់
# អ្វីៗដែលបុរសរាល់រូបត្រូវតែយល់ដឹង
# A User’s Guide

What every man needs to know

## 1. ហេតុអ្វីបានជាបុរសត្រូវតែដឹងយល់ថែមទៀត

សុខភាពល្អមានសារសំខាន់សំរាប់ជីវិតពេញលេញប្រកបដោយសុភមង្គល។ ប៉ុន្តែ គួរឲ្យស្តាយណាស់ ដោយបុរសភាគច្រើនមិនថែទាំខ្លួនឲ្យបានល្អស្រួលបួលឡើយ។ ឧទាហរណ៍ ស្ត្រីដែលមានអាយុពី 25ឆ្នាំ ទៅ 34ឆ្នាំ ទំនងជាទៅជួបវេជ្ជបណ្ឌិតញឹកញាប់ជាងបុរសដែលមានវ័យស្រដៀងគ្នា*ដល់ទៅទ្វេដងឯណោះ។ យ៉ាងណាមិញ បុរសពុំមានអាយុវែងដូចជាស្ត្រីឡើយ ហើយអាចមានបញ្ហាសុខភាពច្រើនជាងស្ត្រីទៀត ដូច្នេះជាការសំខាន់ណាស់ ដែលបុរសត្រូវយល់ដឹងថែមទៀតអំពីការថែរក្សាសុខភាពរបស់ខ្លួន។

សុខភាពផ្លូវភេទរបស់បុរសក៏ជារឿងសំខាន់ខ្លាំងណាស់ផងដែរ។ ប្រព័ន្ធបន្តពូជរបស់បុរសដែលមានដំណើរការធម្មតាមានតួនាទីសំខាន់ ក្នុងវិស័យផ្សេងៗជាច្រើននៃសុខុមាលភាពទូទៅ។  ការយល់ដឹងថែមទៀតអំពីរាងកាយរបស់អ្នក របៀបដែលរាងកាយដំណើរការ និងជំងឺណាខ្លះដែលអាចបៀតបៀនរាងកាយបាននោះ គឺជាជំហានដំបូងនៃការឈានទៅកាន់ជីវិតមួយដែលមានសុខភាពកាន់តែប្រសើរឡើង។

*វិជ្ជាស្ថានអូស្ត្រាលីផ្នែកសុខភាពនិងសុខុមាលភាព, សុខភាពរបស់អូស្ត្រាលី ឆ្នាំ 2002(* Australian Institute of Health and Welfare, Australia’s Health 2002)

## 2. តើអ្វីៗដំណើរការយ៉ាងដូចម្តេច

ខួរក្បាលមានតួនាទីមួយដ៏សំខាន់ក្នុងការគ្រប់គ្រងប្រព័ន្ធបន្តពូជរបស់បុរស។ **ផ្នែកតូចនៃខួរក្បាលខាងក្រោយ (Hypothalamus)** និង**ក្រពេញផេត្យូថារី** ឋិតនៅផ្នែកខាងក្រោមនៃខួរក្បាលខាងក្រោយ ហើយក្រពេញទាំង២នេះធ្វើការរំញោចពងស្វាសឲ្យបង្កើតមេជីវិតនិងអរម៉ូនភេទរបស់បុរសហៅថា ថេស្តូស្តេរ៉ូន (Testosterone) ។

មេលិង្គមានមុខងារ ៣ យ៉ាង៖ បញ្ចេញទឹកកាម បញ្ចេញទឹកនោម និងផ្តល់នូវភាពត្រេកត្រអាលផ្លូវភេទ។

**ពងស្វាស** គឺជាសរីរាង្គ (ក្រពេញ)2 មានទ្រង់ទ្រាយដូចជាពង ឋិតនៅក្នុងស្រោមស្បែកហៅថា ស្រោមពងស្វាសដែលព្យួរពីខាងក្រោយមេលិង្គ។ ពងស្វាសទាំងគូ បង្កើតមេជីវិត (ប្រហែលជា៧០លានក្បាល ជារៀងរាល់ថ្ងៃរហូតទៅដល់វ័យចាស់ជរា) និងអរម៉ូនភេទ ថេស្តូស្តេរ៉ូន។ មេជីវិតនីមួយៗ ត្រូវការពេលប្រមាណជា៧០ថ្ងៃដើម្បីកកើតជាមេជីវិតដែលមានរូបរាងដូចកូនក្អុកនៅក្នុងពងស្វាស។ បន្ទាប់មកមេជីវិតទាំងនោះរំកិលចូលទៅក្នុង**ថង់មេជីវិត** (ប្រវែងជិត ៥ម៉ែត្រ) ដែលជាបំពង់រមូរពត់ពែននៅពីក្រោយពងស្វាសនីមួយៗ។ នៅពេលចូលទៅដល់ថង់មេជីវិតហើយនោះ មេជីវិតទាំងនោះ ក៏សម្ងំបន្ទុំខ្លួនប្រហែលជា១០ថ្ងៃ។

មេជីវិតធ្វើដំណើរពីថង់មេជីវិតចូលទៅបំពង់ដែលគេហៅថា**បំពង់ផ្លូវមេជីវិត** ហើយដែលជាបំពង់ភ្ជាប់ទៅពងស្វាសនីមួយៗ រៀងៗខ្លួន។ ពន្ទាប់មកមេជីវិតទាំងនេះធ្វើដំណើរតាមបំពង់ផ្លូវមេជីវិតទៅកាន់**បំពង់ផ្លូវទឹកកាម**នៅក្នុង**ក្រពេញប្រូស្តាត**។ ក្រពេញប្រូស្តាត ឋិតនៅខាងក្រោមថង់នោម។ ប្រូស្តាតមានទំហំប៉ុនគ្រាប់វល់ណាត់ (walnut) ហើយបង្កើតទឹកម៉្យាងសំបូរទៅដោយថាមពលនៅលាយឡំជាមួយនឹងមេជីវិត។ ទឹកប្រូស្តាតមានផ្ទុកទឹកកាមប្រមាណជាមួយភាគបួន។ **ថង់ទឹកកាម**ក៏បង្កើតទឹកម៉្យាងសំបូរទៅដោយថាមពល ដែលរួមចំណែកដោយទឹកកាមប្រមាណជាពីរភាគបី។  បំពង់ផ្លូវទឹកកាមភ្ជាប់ទៅនឹង**ផ្លូវនោម** ដែលជាបំពង់តែមួយតភ្ជាប់ថង់នោមទៅនឹងចុងក្បាលលិង្គ។ បំពង់ផ្លូវនោមជាបំពង់សំរាប់បង្ហូរទឹកនោមនិងទឹកកាមចេញពីក្នុងខ្លួន។

ថេស្តូស្ត៊ីរ៉ូនគឺជាអ័រម៉ូនភេទបុរសដ៏សំខាន់ក្រៃលែង ហើយចាំបាច់សំរាប់សុខភាពផ្លូវភេទនិងសុខភាពបន្តពូជដ៏ល្អ។ អ័រម៉ូនទាំងឡាយជាភ្នាក់ងារបញ្ជូនសារធាតុគីមីដែលបង្កើតឡើងនៅក្នុងសរីរាង្គមួយហើយបន្ទាប់មកបញ្ជូនដោយឈាមឲ្យទៅធ្វើការនៅតាមសរីរាង្គផ្សេងៗទៀតនៅក្នុងរាងកាយ។ ថេស្តូស្ត៊ីរ៉ូនធ្វើឲ្យរាងកាយមានការផ្លាស់ប្តូរដែលកើតមានឡើងនៅគ្រាដែលកុមារាឆ្លងកាត់វ័យជំទង់ មានដូចជាការធ្វើឲ្យមេលិង្គនិងពងស្វាសឡើងធំ និងធ្វើឲ្យរោមដុះនៅលើមុខនិងរាងកាយជាដើម។ ថេស្តូស្ត៊ីរ៉ូនក៏ជួយធ្វើឲ្យពងស្វាសបង្កើតមេជីវិត ក៏ប៉ុន្តែក៏មានសារសំខាន់សំរាប់ការក្សាសុខភាពទូទៅ ដោយរួមទាំងការរីកលូតលាស់នៃឆ្អឹងនិងសាច់ដុំផងដែរ។

## 3. តើមានអ្វីខ្លះដែលអាចដំណើរមិនល្អ

ដូចជាផ្នែកអ្វីៗផ្សេងទៀតដែលនៅក្នុងរាងកាយមនុស្សយើងដែរ ប្រព័ន្ធបន្តពូជបុរសជួនកាលអាចមិនដំណើរការជាប្រក្រតី។  នៅពេលដែលមានហេតុការណ៍បែបដូច្នេះកើតមានឡើង ការជួបវេជ្ជបណ្ឌិតភ្លាមៗគឺជារឿងសំខាន់ចាំបាច់។ ចំពោះបញ្ហាភាគច្រើន ការស្វែងសុំជំនួយភ្លាមៗ អាចជួយបញ្ចៀសបញ្ហាធ្ងន់ធ្ងរវែងឆ្ងាយទៅថ្ងៃមុខ។ ខាងក្រោមនេះគឺជាបញ្ហាខ្លះ ក្នុងចំណោមបញ្ហាទូទៅបំផុតដែលបុរសអាចជួបប្រទះ៖

## ភាពមិនអាចមានកូន

ជាញឹកញយ បុរសហាក់មានការតក់ស្លុតនៅពេលគេប្រាប់ឲ្យដឹងថា បញ្ហាក្នុងការមានកូន គឺបណ្តាលមកពីបញ្ហានៅក្នុងខ្លួនរបស់គេផ្ទាល់។  **យ៉ាងណាមិញ មានបុរសម្នាក់ក្នុងចំណោមបុរស២០នាក់ នៅក្នុងប្រទេសអូស្ត្រាលីនេះ តាមពិតទៅ ពុំអាចមានកូនបានឡើយ។**

ភាពមិនអាចមានកូនបានរបស់បុរសនេះ អាចបណ្តាលមកពីមូលហេតុច្រើនយ៉ាង ប៉ុន្តែ បញ្ហាពាក់ព័ន្ធនឹងចំនួនឬគុណភាពនៃមេជីវិតដែលបង្កបង្កើតឡើងដោយបុរស គឺជាបញ្ហាទូទៅបំផុត។ ការទប់ទល់ដោះស្រាយនឹងភាពមិនអាចមានកូនរបស់បុរសអាចជារឿងដ៏សែនលំបាក៖ បុរសអាចមានការពិបាកតានតឹងផ្លូវចិត្ត មានការចំបែងថប់ក្នុងចិត្ត ហើយនិងមានអារម្មណ៍គិតថា ជារឿងមួយមិនត្រឹមត្រូវសោះ។ ជាញឹកញយគឺដោយសារនៅក្នុងករណីសឹងតែពាក់កណ្តាល ដែលវេជ្ជបណ្ឌិតមិនអាចពន្យល់អំពីមូលហេតុនៃការបង្កបង្កើតមេជីវិតមិនធម្មតានេះ។  ប៉ុន្តែ វេជ្ជបណ្ឌិតអាចព្យាបាលបញ្ហាខ្លះបាន ហើយគួរមានការពិភាក្សាអំពីបញ្ហានេះជាមួយវេជ្ជបណ្ឌិតជាមុនសិន មុននឹងទៅរកជំនួយបច្ចេកវិទ្យាផ្នែកបន្តពូជ (IVF) ការសុំកូនយកមកចិញ្ចឹម ឬក៏ផ្តល់ខ្លួនធ្វើជាម្តាយឬឪពុកចិញ្ចឹម។

## ប្រូស្តាតឡើងរីកធំ

បញ្ហានេះជាបញ្ហាទូទៅបំផុតចំពោះបុរសវ័យចំណាស់ ដោយមាន**បុរសម្នាក់ក្នុងចំណោមបុរសអូស្ត្រាលីប្រាំពីរនាក់ ដែលមានអាយុលើសពី 40 ឆ្នាំឡើងទៅ នឹងមានបញ្ហាជាមួយប្រូស្តេតរបស់ខ្លួន។** ជំងឺប្រូស្តាតទូទៅបំផុតមួយ ដែលមិនមែនជាមហារីក គឺជំងឺប្រូស្តេតឡើងរីកធំ ដែលគេហៅថា Benign Prostatic Hyperplasia (BPH) ។ ថ្វីបើជំងឺ BPH នេះមិនអាចបណ្តាលឲ្យមានការបាត់បង់ជីវិតក្តី ក៏វាអាចធ្វើឲ្យការបត់ជើងតូច និងការរស់នៅជួបនឹងការលំបាកដែរ។

ការវះកាត់ និង ការប្រើថ្នាំពេទ្យអាចធ្វើទៅបានដោយវេជ្ជបណ្ឌិតដើម្បីធ្វើឲ្យរោគសញ្ញានៃជំងឺប្រូស្តេតនេះធ្លាក់ចុះថយ។ យ៉ាងណាមិញ បញ្ហាបត់ជើងតូចទាំងអស់មិនមែនសុទ្ធតែបង្កឡើងដោយបញ្ហាប្រូស្តាតនោះទេ ដូច្នេះការជួបពិគ្រោះយោបល់ជាមួយនឹងវេជ្ជបណ្ឌិតគឺជារឿងសំខាន់។

## មហារីកប្រូស្តេត

មហារីកប្រូស្តេតគឺជាជំងឺទូទៅ ហើយជារៀងរាល់ឆ្នាំ បុរសប្រមាណជា ១ម៉ឺននាក់ នៅក្នុងប្រទេសអូស្ត្រាលីទទួលនូវដំណឹងថា ខ្លួនមានជំងឺមហារីកប្រូស្តាត។ ជាញឹកញយ មហារីកប្រូស្តាតនេះកើតមានឡើងដោយពុំមានរោគសញ្ញាអ្វីឡើយ ដូច្នេះបុរសគួរគិតគូរអំពីការពិភាក្សាជាមួយវេជ្ជបណ្ឌិតស្តីអំពីការធ្វើតេស្ត ដោយការពិនិត្យមើលតាមរន្ធគូទ និងការធ្វើតេស្តពិនិត្យមើលរោគជាក់លាក់នៅក្នុងប្រូស្តាត ហៅថា Prostate Specific Antigen (PSA) ។ មានការពិភាក្សាវែកញែកជាច្រើនអំពីការធ្វើតេស្ត PSA ដូច្នេះនៅពេលគិតគូរអំពីការធ្វើតេស្តដើម្បីពិនិត្យរកមើលជំងឺមហារីក អ្នកគប្បីធ្វើការពិភាក្សាជាមួយនឹងវេជ្ជបណ្ឌិតណាម្នាក់ដើម្បីឲ្យបានយល់ច្បាស់ថាតើការធ្វើតេស្តនេះនឹងជួយដល់ស្ថានភាពរបស់អ្នកឬយ៉ាងណា។ ការព្យាបាលជំងឺមហារីកប្រូស្តេត អាចមានការវះកាត់ ការព្យាបានដោយការប្រើរស្មី radiation និង "ការរង់ចាំឃ្លាំមើល" ។

## លិង្គមិនឡើងរឹង

បញ្ហាផ្លូវភេទចំពោះបុរសមានសភាពទូទៅជាងអ្វីដែលអ្នកអាចគិតស្មាន។ មាន**បុរសអូស្ត្រាលីប្រហែលជាមួយនាក់ ក្នុងចំណោម ៥ នាក់ ដែលមានអាយុលើសពី ៤០ឆ្នាំ ឡើងទៅ មានបញ្ហាលិង្គមិនឡើងរឹងនេះ (លិង្គងាប់)។**

នៅក្នុងករណីខ្លះ បញ្ហាលិង្គមិនឡើងរឹងនេះគឺជាសញ្ញានៃជំងឺធ្ងន់ធ្ងរមួយផ្សេងទៀត មានដូចជា ទឹកនោមផ្អែម ឬក៏បញ្ហាបេះដូងជាដើម។ បើទុកណាជាមូលហេតុនៃបញ្ហាលិង្គមិនឡើងរឹងនេះបង្ហាញតាមអាការផ្លូវកាយក្តី ក៏ការទទួលជំនួយផ្លូវចិត្ត ឬការប្រឹក្សាផ្តល់ឱវាទខ្លះ ជាផ្នែកដ៏សំខាន់មួយនៃការព្យាបាលដែរ។ មានការព្យាបាលដទៃទៀតជាច្រើនសំរាប់បញ្ហាលិង្គមិនឡើងរឹងនេះ-ដោយរួមទាំងការប្រើថ្នាំពេទ្យផង- ប៉ុន្តែការនិយាយពិគ្រោះជាមួយនឹងដៃគូរួមមេត្រី និង វេជ្ជបណ្ឌិតរបស់អ្នក គឺជាជំហានទីមួយដ៏សំខាន់បំផុត។

## កង្វះអ័រម៉ូនភេទ ថេស្តូស្តេរ៉ូន

កំរិតនៃកម្លាំងធ្លាក់ចុះថមថយ អារម្មណ៍ផ្លាស់ប្តូរមិនទៀងទាត់ ឆាប់ខឹងមួហ្មង (ការខឹងមួម៉ៅ) មានបញ្ហាក្នុងការផ្តង់អារម្មណ៍ កម្លាំងសាច់ដុំធ្លាក់ចុះខ្សោយ ឬក៏ខ្វះចំណាប់អារម្មណ៍ក្នុងការរួមភេទ អាចជាសញ្ញាបង្ហាញថា កំរិតអ័រម៉ូនភេទថេស្តូស្តេរ៉ូនធ្លាក់ចុះទាប (កង្វះអ័រម៉ូនភេទ ថេស្តូស្តេរ៉ូន)។ **បុរសម្នាក់ក្នុងចំណោមបុរសអូស្ត្រាលី**

២០០នាក់មានបញ្ហាអ័រម៉ូនភេទ ថេស្តូស្តេរ៉ូនធ្លាក់ចុះទាប។

បញ្ហាកង្វះអ័រម៉ូនភេទថេស្តូស្តេរ៉ូននេះយាយីបុរសគ្រប់វ័យទាំងអស់ ហើយអាចបណ្តាលមកពីបញ្ហាពន្ធុ (ហ្សែន) ឬក៏បញ្ហាសុខភាព បណ្តាលមកពីការខូចពងស្វាស ឬក៏អាចបណ្តាលមកពីដំណើរចូលវ័យចំណាស់តែម្តង។ ចំពោះបុរសវ័យចំណាស់ខ្លះ កំរិតអ័រម៉ូនភេទ ថេស្តូស្តេរ៉ូន ធ្លាក់ចុះដល់កំរិតដែលតម្រូវឲ្យមានការព្យាបាល។ គេអាចឃើញកង្វះអ័រម៉ូនភេទ ថេស្តូស្តេរ៉ូននេះ តាមតែរយៈការធ្វើរោគវិនិច្ឆ័យប៉ុណ្ណោះ ដោយវេជ្ជបណ្ឌិតដែលអាចផ្តល់ការព្យាបាល ដោយការចាក់ថ្នាំ ការដាក់បញ្ចូលសារធាតុអ័រម៉ូនភេទថេស្តូស្តេរ៉ូន ការប្រើថ្នាំគ្រាប់ ការប្រើបន្ទះថ្នាំបិទ ការប្រើថ្នាំស្អិតខាប់អន្និល។

## មហារីកពងស្វាស

មហារីកពងស្វាសគឺជា**ជំងឺមហារីកទូទៅបំផុតទី២ ចំពោះបុរសអាយុពី 18 ទៅ 39ឆ្នាំ** ។ យ៉ាងណាមិញ គេអាចព្យាបាលជំងឺនេះបានដោយងាយស្រួល ហើយនៅពេលគេរកឃើញដឹងនាគ្រាដំបូងភ្លាមៗនោះ បុរសសឹងតែទាំងអស់ (ចំនួនច្រើនជាង95%) អាចព្យាបាលជាសះស្បើយបាន។ សញ្ញាសាមញ្ញបំផុតនៃជំងឺនេះ គឺការមានដុំរឹង តែមិនឈឺចាប់អ្វីឡើយនៅក្នុងពងស្វាស ក៏ប៉ុន្តែពងស្វាស ក៏អាចមានការឈឺចាប់ និងងាយរងការឈឺចាប់ផងដែរ។ ចំពោះបុរសមួយចំនួនតូច ការឈឺចុករោយខ្នងជាប់ជានិច្ច ក្អកឬដកដង្ហើមដាច់ៗ ដោះឡើងហើម ឬឈឺនៅពេលកាន់ស្វាប(ងាយឈឺចាប់) អាចជាសញ្ញាបង្ហាញថា មហារីកនោះបានធ្វើការរាលដាលទៅដល់ផ្នែកផ្សេងៗទៀតនៃរាងកាយហើយ។  ការវះកាត់ពងស្វាសដែលមានមហារីក គឺជាការព្យាបាលដំបូងសំរាប់ជំងឺមហារីកពងស្វាសទាំងអស់។ ការវះកាត់បែបនេះ ជាទូទៅមិនបណ្តាលឲ្យមានការប្រែប្រួលដល់ការរួមផ្លូវភេទ ឬក៏សមត្ថភាពឡើងរឹងរបស់លិង្គឡើយ។

## 4. របៀបស្វែងរកព័ត៌មានថែមទៀត

ជំហានដ៏សំខាន់បំផុតគឺការទៅជួបវេជ្ជបណ្ឌិតរបស់អ្នក។ ប៉ុន្តែ បើសិនជាអ្នកចង់បានព័ត៌មានបន្ថែមអំពីបញ្ហានេះ សូមបើកមើលវិបសាយរបស់អេនដ្រូឡូជីអូស្ត្រាលី (Andrology Australia) នៅឯ:
www.andrologyaustralia.org

(1) ផ្នែកតូចនៃខួរក្បាលខាងក្រោយ (Hypothalamus)
(2) ក្រពេញផេត្យូថារី
អ័រម៉ូន២យ៉ាង- លូថេណាយហ្សីង (LH) និង ហ្វូលីខល ស្ទីមូលេធីង (FSH)- ដែលចេញមកពីក្រពេញផេត្យូថារី រំញោចឲ្យពងស្វាសបង្កើតអ័រម៉ូនភេទ ថេស្តូស្តេរ៉ូន និងមេជីវិត

(3) អ័រម៉ូនថេស្តូស្តេរ៉ូន
(4) ពងស្វាស






(1) បំពង់ផ្លូវមេជីវិត
(2) ក្រពេញប្រូស្តាត
(3) ផ្លូវនោម
(4) មេលិង្គ
(5) ស្រោមពងស្វាស
(6) ថង់នោម
(7) ថង់ទឹកកាម
(8) បំពង់ផ្លូវទឹកកាម
(9) ក្រពេញខាវពឺរ
(10) ថង់មេជីវិត
(11) ពងស្វាស

អេនដ្រូឡូជី (Andrology) គឺជាការសិក្សាអំពីមុខងារនិងជំងឺពាក់ព័ន្ធនឹងបុរសភេទ ជាពិសេស អំពីសរីរាង្គបន្តពូជ។ ពាក្យនេះមានន័យស្មើគ្នានឹងពាក្យថា ហ្គាយនីខូឡូជី (gynaecology) ដែលជាការសិក្សាអំពីមុខងារនិងជំងឺពាក់ព័ន្ធនឹងស្ត្រីភេទ ជាពិសេសសរីរាង្គបន្តពូជ។

ប័ណ្ណព័ត៌មាននេះរៀបចំឡើងដោយសេវាទំនាក់ទំនងសុខភាពពហុវប្បធម៌រដ្ឋ NSW ដោយមានកិច្ចសហការពីសេវាសុខភាព FPA ( NSW ) ជំនួសឲ្យអេនដ្រូឡូជីអូស្ត្រាលី (Andrology Australia) ។ អេនដ្រូឡូជីអូស្ត្រាលីសូមថ្លែងអំណរគុណដល់ជំនួយចំពោះគំរោងនេះពីបណ្តាអង្គការដែលមានរាយឈ្មោះខាងក្រោមនេះ៖ Multicultural HIV/Hep C, Primary Health & Community Care Branch, NSW Health, NSW Refugee Health Service, Health Promotion Service Community Health Services, WSAHS, MHIRC University of Western Sydney.

អេនដ្រូឡូជីអូស្ត្រាលី (Andrology Australia ) បានទទួលថវិកាពីក្រសួងសុខាភិបាលនិងភាពចាស់ជរានៃរដ្ឋាភិបាលសហព័ន្ធអូស្ត្រាលី ហើយមានបំណងផ្តល់ការអប់រំដល់សហគមន៍និងអ្នកមានមុខវិជ្ជាជីវៈសុខភាពអំពីបញ្ហាសុខភាពបន្តពូជបុរស។

NSW Multicultural Health Communication Service
Website: http://www.mhcs.health.nsw.gov.au
Email: mhcs@sesiahs.health.nsw.gov.au
Tel: (02) 9816 0347

ANDROLOGY AUSTRALIA
Andrology Australia, c/o School of Public Health & Preventive Medicine, Monash University. Address: The Alfred Centre, 99 Commercial Road, Melbourne, VIC 3004. Postal Address: PO Box 315, Prahran, VIC 3181. Phone: 1300 303 878 (cost of a local call).